ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ
ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# របាយការណ៍
# ស្តីពី
# ការវាយតម្លៃលើការអនុវត្តថវិកាកម្មវិធី ប្រចាំឆ្នាំ២០១៥ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦

## ១. សេចក្តីផ្តើម

ឆ្នាំ២០១៥ ជាឆ្នាំដំបូងដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចាប់ផ្តើមអនុវត្តថវិកាកម្មវិធីពេញលេញ។ ក្នុងបរិការណ៍ការងារថ្មីនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០១៥-២០១៧ ដោយដាក់ចេញនូវគោលបំណងគោលនយោបាយចំនួន ២ និងកម្មវិធីចំនួន ៥ និងបានដាក់ឱ្យអនុវត្តអង្គភាពថវិកានៅតាមអគ្គលេខាធិការដ្ឋាន គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន នៅថ្នាក់កណ្តាល និងនៅគ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅថ្នាក់មូលដ្ឋាន។ ដើម្បីចូលរួមចំណែកសម្រេចឱ្យបាននូវគោលបំណងគោលនយោបាយទី២ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺ "ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ" អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) ក្នុងនាមជាសេនាធិការ នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងជាអង្គភាពថវិកាមួយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចូលរួមអនុវត្ត**<u>អនុកម្មវិធីទី ៥.១÷ ទ្រទ្រង់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព</u>** ក្នុងកម្មវិធីទី៥÷ "ការផ្តល់សេវាគាំទ្រទូទៅ និងគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" នៃគោលបំណងគោលនយោបាយទី២។

របាយការណ៍ស្តីពីការវាយតម្លៃលើការអនុវត្តថវិកាកម្មវិធីប្រចាំឆ្នាំ២០១៥ របស់ **អ.គ.ហ** នឹងបង្ហាញពីវឌ្ឍនភាព, បញ្ហាប្រឈម, សំណើដំណោះស្រាយ និងការងារត្រូវធ្វើបន្ត ពាក់ព័ន្ធនឹងកិច្ចដំណើរការរៀបចំ និងអនុវត្តថវិការបស់ខ្លួន ដែលមានខ្លឹមសារដូចខាងក្រោម។

## ២. វឌ្ឍនភាព

### ២.១ ការរៀបចំថវិកា

#### ២.១.១ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (២០១៥-២០១៧)

ក្នុងការអនុវត្តការងាររបស់ខ្លួន **អ.គ.ហ.** បានកំណត់ចក្ខុវិស័យច្បាស់លាស់ ដើម្បីក្លាយជាឧត្តមមជ្ឈមណ្ឌលប្រកបដោយជំនាញដ៏ចំណាន វិជ្ជាជីវភាពខ្ពស់ គុណធមិ សីលធមិ វិន័យ និងសេចក្តីថ្លៃថ្នូរ ក្នុងបុព្វហេតុបម្រើឧត្តមប្រយោជន៍សង្គមជាតិដែលនឹងឈានទៅសម្រេចបាននូវការកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ស្តង់ដារអន្តរជាតិ។ ដើម្បីសម្រេចបានតាមចក្ខុវិស័យដែលបានដាក់ចេញ និងចូលរួមអនុវត្តគោលបំណងគោល-នយោបាយទី២ កម្មវិធីទី៥ នៃផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០១៥-២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, **អ.គ.ហ.** ក្នុងនាមជាអង្គភាពថវិកា ត្រូវទទួលបន្ទុកអនុវត្តអនុកម្មវិធីទី៥.១ ដែលក្នុងនោះ **អ.គ.ហ.** បានរៀបចំចង្កោមសកម្មភាពគាំទ្រចំនួន ០៤ និងសកម្មភាពលម្អិតចំនួន ០៧ និងបានកំណត់សូចនាករសមិទ្ធកម្មច្បាស់លាស់ ដើម្បីវាស់វែងពីការសម្រេចបាននូវគោលដៅសូចនាករនៃចង្កោមសកម្មភាពទាំង៤ នៃអនុកម្មវិធីទី៥.១ ខាងលើ ព្រមទាំងបានរៀបចំគណនាតម្រូវការចំណាយទៅតាមសកម្មភាព ចង្កោមសកម្មភាព និងអនុកម្មវិធី សម្រាប់ទាំងថវិការដ្ឋ និងហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍។

តម្រូវការចំណាយសម្រាប់អនុវត្តអនុកម្មវិធីទី៥.១ ក្នុងឆ្នាំ២០១៥ ត្រូវបានកំណត់ចំនួន ១ ៦៣០ លានរៀល។

#### ២.១.២ ការរៀបចំគម្រោងថវិកាឆ្នាំ២០១៥

ឥណទានថវិកាដែលត្រូវបានអនុម័តសម្រាប់ឆ្នាំ២០១៥ មានសរុបចំនួន ១ ៦២២ ០០០ ០០០ រៀល (មួយពាន់ប្រាំមួយរយម្ភៃពីរលានរៀល) ដើម្បីអនុវត្តអនុកម្មវិធីទី៥.១ ក្នុងនោះ ឥណទានថវិកាសម្រាប់អនុវត្តចង្កោមសកម្មភាព

ទាំង៧ រួមមាន÷ ចង្កោមសកម្មភាពទី១ ចំនួន ៧២ ០០០ ០០០ រៀល, ចង្កោមសកម្មភាពទី២ ចំនួន ៥២៨ ០០០ ០០០ រៀល, ចង្កោមសកម្មភាពទី៣ ចំនួន ៧០២ ០០០ ០០០ រៀល និងចង្កោមសកម្មភាពទី៤ ចំនួន ៣២០ ០០០ ០០០ រៀល។

## ២.២. ការអនុវត្តថវិកា

ក្នុងការអនុវត្តថវិកា អគ្គលេខាធិការ នៃ **អ.គ.ហ.** ត្រូវបានប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិលើឥណទានថវិការបស់ខ្លួន តាមរយៈប្រកាសលេខ ២៥៧ សហវ.ប្រក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៥ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ប៉ុន្តែដោយសង្កេតឃើញកិច្ចប្រឈម ក្នុងការកត់ត្រាកិច្ចបញ្ជិការគណនេយ្យ, ការអនុវត្តថវិកាតាមកម្មវិធី និងកិច្ចដំណើរការសវនកម្មគម្រោង និងដើម្បីបង្ហាញនូវការចូលរួមផ្នែកហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ **អ.គ.ហ.** ត្រូវបានកំណត់ឱ្យអនុវត្តថវិកាតាមនីតិវិធីរួមបច្ចុប្បន្នកម្ម ដែលរួមមានការគ្រប់គ្រងគម្រោង, ការគ្រប់គ្រងហិរញ្ញវត្ថុគម្រោង និងកិច្ចលទ្ធកម្មគម្រោង ទាំងសម្រាប់ថវិការដ្ឋ និងហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ តាមរយៈប្រកាសលេខ៣៣០ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តនីតិវិធីរួមបច្ចុប្បន្នកម្មនៅក្នុងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងន័យនេះ កញ្ចប់ថវិកាដែលមានទំហំស្មើនឹងឥណទានថវិកាប្រចាំឆ្នាំ២០១៥ របស់ **អ.គ.ហ.** ត្រូវបានផ្ទេរចូលក្នុងគណនីនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅធនាគារជាតិនៃកម្ពុជា ដើម្បីអនុវត្តតាមនីតិវិធីរួមបច្ចុប្បន្នកម្ម។

ទោះយ៉ាងណា **អ.គ.ហ.** នៅតែបន្តកត់ត្រាការអនុវត្តថវិកា ទៅតាមមាតិកាសេដ្ឋកិច្ច និងមាតិកាកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព ស្របតាមការកំណត់ក្នុងនីតិវិធីអនុវត្តថវិកាកម្មវិធី និងសម្រេចបានលទ្ធផលដូចខាងក្រោម÷

**អនុកម្មវិធីទី ៥.១÷** "ទ្រទ្រង់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព"។

- ឥណទានថវិកាក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៥ មានចំនួន ១ ៦២២ ០០០ ០០០ រៀល
- វឌ្ឍនភាពនៃការអនុវត្តអនុកម្មវិធី៥.១ សម្រេចបាន ៧៦% ធៀបនឹងគោលដៅសូចនាករក្នុងឆ្នាំ
- ការអនុវត្តថវិកា សម្រេចបាន ៦៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ។

ឥណទានថវិកាខាងលើ ត្រូវបានវិភាជសម្រាប់គាំទ្រការអនុវត្តចង្កោមសកម្មភាពទាំង៤ និងសម្រេចបានជាលទ្ធផលដូចខាងក្រោម÷

**ចង្កោមសកម្មភាពទី១÷** "រៀបចំកម្មវិធីផ្សព្វផ្សាយស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមរយៈការធ្វើសិក្ខាសាលា សន្និសីទ ការចុះទៅធ្វើបទឧទ្ទេសនាមតាមក្រសួង-ស្ថាប័ន គ្រឹះស្ថានសិក្សា និងសាធារណៈ"

- ចង្កោមសកម្មភាពនេះ ត្រូវបានវិភាជថវិកាចំនួន ៧២ ០០០ ០០០ រៀល
- វឌ្ឍនភាពនៃការអនុវត្តចង្កោមសកម្មភាព សម្រេចបាន ៦៧% ធៀបនឹងគោលដៅសូចនាករក្នុងឆ្នាំ
- ពុំបានប្រើប្រាស់ថវិការដ្ឋដើម្បីគាំទ្រសកម្មភាពនេះឡើយ ដោយមូលហេតុថាសកម្មភាពទាំងនេះត្រូវបានអនុវត្តដោយថវិកាដៃគូអភិវឌ្ឍន៍ជំនួសវិញ។

**ចង្កោមសកម្មភាពទី២÷** “អនុវត្តកិច្ចដំណើរការរបស់ **អ.គ.ម.** ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព”

- ចង្កោមសកម្មភាពនេះ ត្រូវបានវិភាជថវិកាចំនួន ៥២៨ ០០០ ០០០ រៀល
- វឌ្ឍនភាពនៃការអនុវត្តចង្កោមសកម្មភាព សម្រេចបាន ១០០% ធៀបនឹងគោលដៅសូចនាករក្នុងឆ្នាំ
- បានប្រើប្រាស់ថវិការដ្ឋសរុប ៧៦៨ ៥១៩ ៤០០ រៀល ស្មើនឹង ១៤០% នៃច្បាប់ហិរញ្ញវត្ថុ។ ការអនុវត្តថវិកាលើសការកំណត់ ដោយហេតុថា មានតម្រូវការរៀបចំកិច្ចប្រជុំលើសពីការគ្រោងទុក និងប្រភេទចំណាយមួយចំនួនពុំទទួលបានការគាំទ្រពីថវិកាដៃគូអភិវឌ្ឍន៍ឡើយ។

**ចង្កោមសកម្មភាពទី៣÷** “អនុវត្តកិច្ចដំណើរការផែនការសកម្មភាពដំណាក់កាលទី២ ថ្មី (GDAP2-New) និងត្រៀមរៀបចំដំណាក់កាលទី៣”

- ចង្កោមសកម្មភាពនេះ ត្រូវបានវិភាជថវិកាចំនួន ៧០២ ០០០ ០០០ រៀល
- វឌ្ឍនភាពនៃការអនុវត្តចង្កោមសកម្មភាព សម្រេចបាន ៨៧% ធៀបនឹងគោលដៅសូចនាករក្នុងឆ្នាំ ដោយសារការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី២ថ្មី និងការធ្វើផែនការសកម្មភាពលម្អិតរបស់អង្គភាពក្រោមឱវាទ គសហវ. និងក្រសួង-ស្ថាប័នមិនទាន់បញ្ចប់ពេញលេញនៅឡើយ
- បានប្រើប្រាស់ថវិការដ្ឋសរុបចំនួន ២៨១ ៤០៥ ៦០០ រៀល ស្មើនឹង ៤០% នៃច្បាប់ហិរញ្ញវត្ថុ ដោយហេតុថា ការជ្រើសរើសមន្ត្រីជំនាញបន្ថែមមានការយឺតយ៉ាវ។ ថវិកានៅសល់មានចំនួន ៤២០ ៥៩៤ ៤០០ រៀល។

**ចង្កោមសកម្មភាពទី៤÷** “វាយតម្លៃប្រចាំឆ្នាំអំពីប្រសិទ្ធភាពនៃការប្រើប្រាស់ជំនួយបច្ចេកទេស និងការបណ្តុះបណ្តាល សម្រាប់រៀបចំផែនការកសាងសមត្ថភាពរបស់ **អ.គ.ម.**”

- ចង្កោមសកម្មភាពនេះ ត្រូវបានវិភាជថវិកាចំនួន ៣២០ ០០០ ០០០ រៀល
- វឌ្ឍនភាពនៃការអនុវត្តចង្កោមសកម្មភាពនេះសម្រេចបាន ២០% ធៀបនឹងគោលដៅសូចនាករប្រចាំឆ្នាំ ដោយសារតែការវិភាគតម្រូវការកសាងសមត្ថភាពនៅមិនទាន់បានរៀបចំ
- បានប្រើប្រាស់ថវិការដ្ឋសរុបមានចំនួន ៣៨ ៦៥២ ៨៤០ រៀល ស្មើនឹង ១២% នៃច្បាប់ហិរញ្ញវត្ថុ។ ការប្រើប្រាសថវិកានេះ នៅសល់ប្រមាណ ៨៨% នៃផែនការ ដោយសារសកម្មភាពពាក់ព័ន្ធនឹងការបណ្តុះបណ្តាលភាគច្រើនត្រូវបានប្រើប្រាស់ថវិកាពីដៃគូអភិវឌ្ឍន៍ជំនួស។ ថវិកានៅសល់មានប្រមាណ ២៨១ ៣៤៧ ១៦០ រៀល ។

## ៣. បញ្ហាប្រឈម

ក្នុងដំណាក់កាលដំបូងនៃការអនុវត្តថវិកាកម្មវិធី **អ.ត.ម.** បានជួបប្រទះបញ្ហាប្រឈមមួយចំនួន ទាំងក្នុងការរៀបចំ និងការអនុវត្តថវិកាដូចខាងក្រោម÷

- យន្តការ និងបច្ចេកទេសក្នុងការរៀបចំសូចនាករ និងគោលដៅសូចនាករនៅមានកម្រិត។ ការវិភាជថវិកា និងទម្រង់សម្រាប់ការរៀបចំថវិកា (ឯកសារឧបសម្ព័ន្ធដែលត្រូវបំពេញ) មានចំនួនច្រើន មានភាពស្មុគស្មាញ និងត្រូវបានផ្លាស់ប្ដូរញឹកញាប់ ដែលបង្កឱ្យមានការលំបាកក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ
- ភាពស្មុគស្មាញក្នុងការស្នើសុំកញ្ចប់ថវិកាពីអគ្គនាយកដ្ឋានថវិកា និងការផ្ទេរប្រាក់ពីរតនាគារជាតិ មក **អ.ត.ម.** ដែលបង្កឱ្យមានផលវិបាកក្នុងការប្រើប្រាស់ថវិកាដើម្បីទ្រទ្រង់សកម្មភាពដែលបានដាក់ចេញឱ្យទាន់ពេលវេលាកំណត់
- មន្ត្រីផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ **អ.ត.ម.** សុទ្ធតែជាបុគ្គលិកជាប់កិច្ចសន្យា ដែលមិនអាចឆ្លើយតបតាមនីតិវិធីនៃការអនុវត្តថវិកាកម្មវិធី ជាអាទិ៍ ការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន, រដ្ឋទេយ្យករបុរេប្រទានរង, ក្រុមលទ្ធកម្ម, ការងារកត់ត្រាកិច្ចបញ្ជិការគណនេយ្យ ជាដើម
- ការប្រើប្រាស់ថវិកាលើសគម្រោង ដែលតម្រូវឱ្យធ្វើនិយ័តភាព
- ការប្រើប្រាស់ថវិកាពីប្រភពដទៃ ដែលបង្កឱ្យមិនអាចសម្រេចបាននូវការអនុវត្តថវិកាតាមផែនការ។

## ៤. សំណើដំណោះស្រាយ

- ស្នើឱ្យផ្នែកនីមួយៗនៃ **អ.ត.ម.** ពង្រឹងការតាមដានអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យបានទៀងទាត់ ជាប្រចាំត្រីមាស ដើម្បីតាមដានវឌ្ឍនភាពសម្រេចបាន និងត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ និងកំណត់បញ្ហាប្រទាក់ក្រឡាគ្នារវាងអង្គភាពក្រោមឱវាទ ដើម្បីធានាប្រសិទ្ធភាព និងគុណភាពការងារ
- ស្នើគ្រប់អង្គភាពពាក់ព័ន្ធនៃ **អ.ត.ម.** រៀបចំផែនការសកម្មភាពឱ្យបានគ្រប់ជ្រុងជ្រោយនិងអនុវត្តតាមផែនការជាអតិបរមា។

## ៥. ការងារត្រូវធ្វើបន្ត

- រៀបចំ ចងក្រង និងដាក់ឱ្យអនុវត្តសៀវភៅ "ចក្ខុវិស័យ និង យុទ្ធសាស្ត្រ" សម្រាប់ឆ្នាំ២០១៦-២០១៨
- ពង្រឹងគុណភាពការងារកែទម្រង់ ការងារប្រចាំថ្ងៃ និងការងារជាយថាហេតុ (Ad-hoc) ប្រកបដោយប្រសិទ្ធភាពខ្ពស់
- បន្តអនុវត្តបញ្ចប់ការងារដែលនៅសេសសល់ ដូចជា ការវិភាគតម្រូវការកសាងសមត្ថភាព និងតម្រូវការជំនួយបច្ចេកទេសជាដើម
- បន្តពង្រឹងការអនុវត្តថវិកាកម្មវិធីឱ្យបានពេញលេញ ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

## ៦. សន្និដ្ឋាន

ក្នុងដំណាក់កាលនៃការអនុវត្តថវិកាកម្មវិធីដំបូង **អ.គ.ហ.** បានអនុវត្តថវិកាកម្មវិធីសម្រេចបានតាមគោលដៅសូចនាករដែលបានដាក់ចេញ គួរជាទីមោទនៈ ដោយសម្រេចបាន **៧៦%** នៃសូចនាករប្រចាំឆ្នាំសម្រាប់ការអនុវត្តអនុកម្មវិធីទី៥.១ "ទ្រទ្រង់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈប្រកបដោយប្រសិទ្ធិភាព និងស័ក្តិសិទ្ធភាព" បើទោះបីជាជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនក៏ដោយ។ ទន្ទឹមនេះ **អ.គ.ហ.** បានស្នើឱ្យគ្រប់អង្គភាពក្រោមឱវាទ ត្រូវបញ្ចប់សកម្មភាពដែលនៅសេសសល់, បន្តពង្រឹងគុណភាពការងារ ជាពិសេស ពង្រឹងការរៀបចំ និងការអនុវត្តថវិកាកម្មវិធីឱ្យបានជាអតិបរមា។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦

អ្នករៀបចំរបាយការណ៍

**សុគន្ធ ចរិយា**

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦

**អគ្គលេខាធិការស្តីទី**

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារ**

**កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត ហ៊ែល ចំរើន**

ឧបសម្ព័ន្ធ នៃរបាយការណ៍ស្តីពីការវាយតម្លៃលើការអនុវត្តថវិកាកម្មវិធីប្រចាំឆ្នាំ២០១៥ របស់ អ.គ.ហ.

| អនុកម្មវិធី | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៥ (រៀល) | សូចនាករគន្លឹះប្រចាំឆ្នាំ (ដែលបានកំណត់) | វឌ្ឍនភាពសម្រេចបាន | វឌ្ឍនភាពធៀបនឹងសូចនាករ | ឥណទានអនុវត្តជាក់ស្តែង (រៀល) | ប្រៀបធៀប ឥ.ច្បាប់/អនុវត្តជាក់ស្តែង (%) |
|---|---|---|---|---|---|---|
| **អនុកម្មវិធីទី៥.១ ទ្រទ្រង់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព** | 1,622,000,000 | ១) កិច្ចដំណើរការនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានធានាប្រកបដោយនិរន្តរភាពនិងប្រសិទ្ធភាព<br>២) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធគ្រប់គ្រង ផ្ទៃក្នុងត្រូវបានត្រួតពិនិត្យ កែលម្អ និងដាក់អនុវត្ត | ១) កិច្ចដំណើរការនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានធានាប្រកបដោយនិរន្តរភាពនិងប្រសិទ្ធភាព<br>២) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងប្រព័ន្ធគ្រប់គ្រង ផ្ទៃក្នុងត្រូវបានត្រួតពិនិត្យ កែលម្អ និងដាក់ឱ្យអនុវត្ត | 76% | 1,088,577,840 | 67% |
| ចង្កោមសកម្មភាពទី១: រៀបចំកម្មវិធីផ្សព្វផ្សាយស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការធ្វើសិក្ខាសាលា សន្និសីទ ការចុះទៅធ្វើបទឧទ្ទេសនាមតាមក្រសួង ស្ថាប័ន គ្រឹះស្ថានសិក្សា និងសាធារណៈ | 72,000,000 | ការយល់ដឹងនិងការចូលរួមរបស់មន្ត្រីរាជការ និស្សិត និងសាធារណជនអំពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានការកើនឡើង | ការយល់ដឹងនិងការចូលរួមរបស់មន្ត្រីរាជការ និស្សិត និងសាធារណៈជនអំពីកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានការកើនឡើងតាមរយៈកិច្ចប្រជុំនានា ក៏ដូចជាវេទិកាសាធារណៈផងដែរ | 67% | 0 | 0% |

| | | | | | | |
|---|---|---|---|---|---|---|
| ចង្កោមសកម្មភាពទី២: អនុវត្តកិច្ចដំណើរការរបស់ អ.គ.ហ ប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព | 528,000,000 | កិច្ចដំណើរការរបស់ អ.គ.ហ ត្រូវបានពង្រឹង | -បន្តអនុវត្តតាមចក្ខុវិស័យនិងយុទ្ធសាស្ត្រដើម្បីទ្រទ្រង់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណត់ទិសដៅសម្រាប់ដំណាក់កាលបន្ត<br>-វាយតម្លៃវឌ្ឍនភាពប្រចាំត្រីមាស និងប្រចាំឆ្នាំ ព្រមទាំងដឹកនាំការងារសម្របសម្រួលប្រចាំថ្ងៃជាមួយអគ្គនាយកដ្ឋានដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | 100% | 768,519,400 | 146% |
| ចង្កោមសកម្មភាពទី៣: អនុវត្តកិច្ចដំណើរការផែនការសកម្មភាពដំណាក់កាលទី២ ថ្មី (GDAP2-New) និងត្រៀមរៀបចំដំណាក់កាលទី៣ | 702,000,000 | • GDAP2 New ត្រូវបានផ្សព្វផ្សាយនិងដាក់ឱ្យ អនុវត្តប្រកប ប្រសិទ្ធិភាព និង ស័ក្តិសិទ្ធភាព<br>• ផែនការសកម្មភាពដំណាក់កាលទី៣ត្រូវបានរៀបចំ | -ក្រុមការងារចុះតាមអគ្គនាយកដ្ឋានដើម្បីត្រួតពិនិត្យវឌ្ឍនភាពជាក់ស្តែងធៀបនឹង GDAP 2-New និងផ្តល់ជំនួយសម្រាប់ការរៀបចំដំណាក់កាលទី៣<br>- អង្គភាពក្រោមឱវាទ កសហវ. និងក្រសួង-ស្ថាប័ន បានអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី២ថ្មី (សម្រេចបានប្រហែល ៨0%)<br>-ផែនការសកម្មភាពរួមដំណាក់កាលទី៣ត្រូវរៀបចំនិងអនុម័តដោយគណៈកម្មាធិការដឹកនាំការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | 87% | 281,405,600 | 40% |

| | | | | | | |
|---|---|---|---|---|---|---|
| | | | (សម្រេចបាន១០០%)<br>- ផែនការលម្អិតរបស់អង្គភាពក្រោមឱវាទកសហវ. (GDAP3) និងក្រសួង-ស្ថាប័ន (MAP3) ត្រូវបានរៀបចំ (សម្រេចបាន ៨០%) | | | |
| ចង្កោមសកម្មភាពទី៤: វាយតម្លៃប្រចាំឆ្នាំអំពីប្រសិទ្ធភាពនៃការប្រើប្រាស់ជំនួយបច្ចេកទេស និងការបណ្តុះបណ្តាល សម្រាប់រៀបចំផែនការកសាងសមត្ថភាព របស់ អ.គ.ហ | 320,000,000 | តម្រូវការនៃការកសាងសមត្ថភាពនិងតម្រូវការជំនួយបច្ចេកទេសសម្រាប់បន្តគាំទ្រដល់ការអនុវត្តផែនការសកម្មភាពដំណាក់កាលទី២ និងដំណាក់កាលទី៣ ត្រូវបានរៀបចំប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព | -ថ្នាក់ដឹកនាំ មន្ត្រីជំនាញ និង មន្ត្រីរដ្ឋបាលហិរញ្ញវត្ថុរបស់អ.គ.ហ បានចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លីដើម្បីបង្កើនសមត្ថភាពនៃការផ្តល់ជំនួយបច្ចេកទេស (ថវិកាដៃគូបានរួមវិភាគទានយ៉ាងច្រើនក្នុងសកម្មភាពនេះ)<br>-បានរៀបចំសារាចរស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>- បានរៀបចំសារាចរស្តីពីយន្តការដោះស្រាយកិច្ចប្រឈមក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>- បានចូលរួមកិច្ចប្រជុំតាមដានវឌ្ឍនភាព | 20% | 38,652,840 | 12% |

| | | | | | | |
|---|---|---|---|---|---|---|
| | | | ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមអង្គភាពក្រោមឱវាទ កសហវ។<br>- ថ្នាក់ដឹកនាំ, មន្ត្រីជំនាញជាន់ខ្ពស់ និងមន្ត្រីជំនាញ នៃ អ.គ.ហ បានចូលរួមវគ្គបណ្តុះ-បណ្តាលស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃប្រទេសសិង្ហបុរី។<br>- បានចូលរួមជាមួយលេខាធិការដ្ឋានកំណែទម្រង់រដ្ឋបាលសាធារណៈក្នុងការរៀបចំកម្រងសំណួរសម្រាប់បណ្តុះបណ្តាលសមត្ថភាពមន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ | | | |

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦

**ប្រធានអង្គភាពថវិកា**

**អគ្គលេខាធិការស្តីទី នៃ អ.គ.ហ**

**បណ្ឌិត ហ៊ើល ចំរើន**

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦

អ្នករៀបចំរបាយការណ៍

**សុគន្ធ ចរិយា**